01425247

E321/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 03 / 2017
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៧

**ផ្ញើជូន៖** ឯកឧត្តម ក្រាញ់ តូនី
ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល
លោក Knut ROSANDHAUG
អនុប្រធានការិយាល័យរដ្ឋបាល

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រី ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
លោក Isaac ENDELEY ប្រធានអង្គភាពគាំពារការការពារក្តី
ភាគីទាំងអស់នៃសំណុំរឿង ០០២

**កម្មវត្ថុ៖** សេចក្តីសម្រេចបញ្ចប់ការតែងតាំងមេធាវីប្រចាំការសម្រាប់ ខៀវ សំផន

១. អង្គជំនុំជម្រះរម្លឹកថា នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានបង្គាប់ឱ្យតែងតាំងមេធាវីប្រចាំការសម្រាប់ ខៀវ សំផន ដើម្បីរៀបចំ និងត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលការងារជាមេធាវីការពារក្តីរបស់គាត់នៅគ្រប់ពេលវេលា ប្រសិនបើអង្គជំនុំជម្រះសម្រេចថា វាមានភាពចាំបាច់ក្នុងការជំនួសមេធាវីបច្ចុប្បន្ន (ឯកសារ E321/2)។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះផ្អែកទៅលើសំអាងហេតុដែលថា ការប្រព្រឹត្តិរបស់ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ បានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីនៅក្នុងរយៈពេលពីរខែមុនការ

ចេញសេចក្តីសម្រេចតែងតាំងនេះ ដែលក្នុងអំឡុងពេលនោះមេធាវីការពារក្តីរបស់ ខៀវ សំផន ខកខានមិនបានជួយដល់ជនជាប់ចោទក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះសំណុំរឿង០០២/០២ ទេ។ បន្ទាប់ពីមានការស្វែងរកដោយអង្គភាពគាំពារការការពារក្តី ដើម្បីអនុវត្តតាមដីកាបង្គាប់របស់អង្គជំនុំជម្រះរួចមក នៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៥ លោកស្រី ទូច វរល័ក្ស និង លោក Calvin SAUNDERS ក៏ត្រូវបានតែងតាំងជាមេធាវីប្រចាំការជាតិ និងមេធាវីប្រចាំការអន្តរជាតិ (ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២)។ ចាប់តាំងពីពេលនោះមក កាលៈទេសៈមិនបានតម្រូវឱ្យមេធាវីប្រចាំការជំនួសមេធាវីរបស់ ខៀវ សំផន បច្ចុប្បន្ននេះឡើយ។

២. បន្ទាប់ពីការបិទបញ្ចប់សវនាការដេញដោលពិនិត្យភ័ស្តុតាងនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ រួចមក ដំណាក់កាលខាងមុខនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នោះគឺ ការដាក់សារណាជាលាយលក្ខណ៍អក្សរបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីនៅត្រឹមថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ និងការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលដែលនឹងចាប់ផ្តើមនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧។ អង្គជំនុំជម្រះរំឭកបន្ថែមទៀតថា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ឯកសារ E439/5 អង្គជំនុំជម្រះបានសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងអស់ពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ ដែលមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៩*ស្ទួនបី*(៣) នៃវិធានផ្ទៃក្នុង។

៣. អង្គជំនុំជម្រះយល់ឃើញថា បន្ទាប់ពីមានការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរួចហើយ មូលដ្ឋានដែលតម្រូវឱ្យរក្សាទុកមេធាវីប្រចាំការសម្រាប់ ខៀវ សំផន នឹងលែងមានតទៅទៀតហើយ។ ហេតុនេះ អង្គជំនុំជម្រះបញ្ចប់ការតែងតាំងមេធាវីប្រចាំការជាតិ និងអន្តរជាតិសម្រាប់ ខៀវ សំផន ដោយអង្គភាពគាំពារការការពារក្តី ដែលមានសុពលភាពចាប់ពីថ្ងៃដាក់សារណាជាលាយលក្ខណ៍អក្សរបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ជនជាប់ចោទ។

៤. អង្គជំនុំជម្រះស្នើសុំឱ្យការិយាល័យរដ្ឋបាលចាត់គ្រប់វិធានការចាំបាច់ ដើម្បីជួយសម្រួលដល់ការអនុវត្តសេចក្តីសម្រេចនេះ។